# ដំណាំត្រសក់ស្រូវ



## I. ស្ថានភាពទូទៅ

ត្រសក់ស្រូវជាប្រភេទដំណាំមួយ ដែលត្រូវបានគេនិយមចូលចិត្តបរិភោគ ទាំងផ្លែខ្ចី និងផ្លែទុំ ។ វាត្រូវបានក្រុមអ្នកវិទ្យាសាស្ត្រចាត់បញ្ចូលទៅក្នុងគ្រួសារ Cucurbitaceae លំដាប់ជាក្រុម Cucumis Spp ដែលមានឈ្មោះវិទ្យាសាស្ត្រហៅថា Cucumis milo (Naudian ១៨៥៩ និង Kurz ១៨៧៧)។ ការនិយមចូលចិត្តទាំងផ្លែខ្ចី និង ទុំដោយសារតែមានសារធាតុចិញ្ចឹមច្រើនយ៉ាងដែលផ្តល់អត្ថប្រយោជន៍ ដល់សរីរាង្គកាយ ។ ក្នុងទំងន់ ១០០ក្រាម ដែលបរិភោគបានមានសារធាតុសំខាន់ៗដូច ក្នុងតារាងខាងក្រោម:



**តារាងអាហារូបត្ថ**

| ផ្នែកបរិភោគ | ទឹក | ថាមពល | ប្រូតេអ៊ីន | ប្រេង | សរសៃ | កាបូអ៊ីដ្រាត | រ៉ែផ្សេងៗ |
|---|---|---|---|---|---|---|---|
| ទំងន់ | ក្រាម | កាឡូរី | ក្រាម | ក្រាម | ក្រាម | ក្រាម | ក្រាម |
| ១០០ក្រាម | ៩៥.២ | ២២០ | ០.៣ | ០.២ | ០.៤ | ៣.៥ | ០.៤ |

| ផ្នែកបរិភោគ | Ca | P | Fe | Caro | Thiamin | Ribo | Nia | Vic |
|---|---|---|---|---|---|---|---|---|
| ទំងន់ | mg | mg | mg | Ug | mg | mg | mg | mg |
| ១០០ក្រាម | ៣២ | ១៤ | ១.៤ | ១៦៥ | ០.១១ | ០.០៨ | ០.៣ | ២៦ |



## II. បច្ចេកទេសដាំដុះ

### ១- ការជ្រើសរើសពូជ

ដើម្បីឱ្យការដាំដុះទទួលបានលទ្ធផលល្អ ការជ្រើសរើសពូជជាបញ្ហាចំបង ព្រោះពេលបច្ចុប្បន្ននេះ មានប្រភេទពូជជាច្រើន ដោយរាប់បញ្ចូលទាំងក្នុងស្រុក និងពូជនាំចូល ពូជក្នុងស្រុកជាពូជគ្មានជំនាន់ ហៅថាពូជបង្កាត់សេរី OPV តែដោយ ឡែកពូជនាំចូលភាគច្រើនជាពូជកូនកាត់មានជំនាន់ Hybrid F ។តែទោះជាមានការនាំចូលពីប្រទេសនានា ក៏កសិករកម្ពុជាយើងនៅតែធ្វើការដាំដុះពូជប្រពៃណីយ៉ាងច្រើនលើសលប់ ព្រោះគេអាចរក្សាទុកដោយខ្លួនឯងបាន ប្រសើរជាការដាំពូជនាំចូលព្រោះ វាមានភាពបន្សាំទៅនឹងលក្ខខណ្ឌអាកាសធាតុជាច្រើនជំនាន់រួចមកហើយ ។



ការជ្រើសរើសពូជត្រូវអនុវត្តន៍តាមវិធីសាស្ត្រណែនាំសំខាន់ៗដូចខាងក្រោម:

- អត្រាដំណុះ ពូជដែលអាចយកទៅដាំបានមាន ភាគរយដំណុះ ពី ៨៥-៥%។
- ភាពសុទ្ធនៃពូជ: ពូជត្រូវបានជំរើស និង សំរិទ្ធសំរាំងតាមបច្ចេកទេសនៃពូជ ត្រឹមត្រូវគ្មានជាប់មកជាមួយនូវភ្នាក់ងារបន្តពោគ និងសត្វល្អិតចង្រៃផ្សេងៗ។
- អាយុកាលទុកដាក់: ជាធម្មតាពូជត្រសក់ស្រូវមានដំណេកគ្រាប់យូរខែជាងពូជត្រសក់ឯទៀតចន្លោះពី ៦-៨ ជាមធ្យម (Seed Dormancy) ទើបអាចមានលទ្ធភាពបន្តពូជបាន បើពុំទាន់ផុតដំណេកត្រសក់មិនអាចផលិតបានផ្កាញីឡើយ ។

### ២- ការជ្រើសរើស និងរៀបចំដី



គ្នាល្អ១ហ.ត ប្រើពូជ ១,៨-២,២ គ.ក្រ ។ ពេលយកទៅដាំត្រូវលាយជាមួយថ្នាំការពារ ជំងឺផ្សិតបន្តិចៗ (១គ.ក្រពូជ = ២-៣ ក្រាមថ្នាំ )។ ចំពោះរណ្តៅនៅលើរងត្រូវយក ដីធម្មជាតិទៅដាក់បាតរណ្តៅ ដោយលាយជាមួយគ្រាប់ថ្នាំ Furadan បន្តិចៗក្នុងករណីធ្វើទៅ បានយកជីផូស្វាតទៅលាយជាមួយជីធម្មជាតិក្នុងកំរិត ១០០-១៥០គក្រ ១ហត ហើយលុបដីឱ្យជិត និងដាំដុះតាមក្រោយ មួយរណ្តៅចំនួន ៣-៤គ្រាប់ ជំរៅ ២-៣ សម ដោយគ្របកំទិចចំបើងស្ងួតពីលើហើយស្រោចទឹកផ្សើមរណ្តៅឱ្យសើម។



ត្រសក់ស្រូវក៏ដូចជាត្រសក់ឯទៀតដែរ វាជាប្រភេទរុក្ខជាតិប្រចាំរដូវមានប្រពន្ធ័ឫសរាក់ បរិមាណឫស សំយោគតិចអាយុកាលនៃការបន្តពូជរហ័ស ដូចនេះវាទាម ទារនូវប្រភេទដីដែលផ្តល់សក្តានុពលពីធម្មជាតិបានជា បង្គួរ ។ ដូចនេះគេត្រូវធ្វើការ ជ្រើសរើសដីឱ្យសមស្របដូចជា មានជីជាតិពីធម្មជាតិស្រទាប់ដាំដុះជ្រៅជ្រាបទឹក រហ័ស ភាគច្រើនជាប្រភេទដីក្រហមខ្ពង់រាប ដីភ្នំដីល្បាយខ្សាច់ និងដីល្បាប់មាត់ ទន្លេ ស្ទឹង បឹង ជាដើម សំបូរ ទៅដោយសារធាតុមមោក ត្រសក់ស្រូវស្ថិតនៅក្នុងក្រុម ធន់ទ្រាំមធ្យមទៅនឹងភាពអាស៊ីតនៃដី អាចដុះលូតលាស់បានចន្លោះ pH ៥,៥-៦,៨ ដើម្បីឱ្យការដាំដុះប្រព្រឹត្តិទៅបាន គេត្រូវរៀបចំដីឱ្យបានល្អ ដោយរាស់ប្រមូលយកស្មៅ កាកសំណល់ផ្សេងៗចេញពីចំការ ភ្ជួរដីឱ្យជ្រៅ ហាលដីឱ្យស្ងួតបានច្រើនលើក រាស់បំបែកដីឱ្យល្អិត និង ច្រើនសារហើយលើកជារង ដែលមានកំពស់ ២០-២៥ស.មទទឹងរង ១២០-១៥០សម កៀរដីឱ្យ ស្មើលើរងនិមួយៗបន្ទាប់មកកាប់ជារណ្តៅចំកណ្តាលរងជំរៅ១០-១៥សម ចន្លោះពីរណ្តៅមួយទៅមួយ៧០សម ។

### ៣- ការដាំដុះ

មុននឹងដាំគេត្រូវយកគ្រាប់ពូជមកសំអាតជាមុន ហើយដាក់ហាលថ្ងៃឱ្យក្តៅ រយៈពេល ១-២ម៉ោង ក្រោយមកយកទៅត្រាំទឹក ៤-៥ម៉ោង ហើយលាងសំអាត នឹងទឹកឱ្យស្អាតចំនួន ៣-៤លើក ទើបយកទៅផ្អាប់ ទុក១យប់ដើម្បីឱ្យគ្រាប់ពូជ មានការវិវត្តន៍ផ្នែកអំប្រ៊ីយ៉ុង តាមរយៈកំដៅ និងសំណើមធ្វើឱ្យត្រសក់ដុះស្មើ។

របៀតដល់ប្រមូលផលវាទាមទារនូវសំណើមយ៉ាងល្អសំរាប់ជំនួយដល់ការបន្តពូជកាល ណាកង្វះទឹកក្នុងវគ្គនេះធ្វើឱ្យបាត់បង់នូវភាគរយយ៉ាង ច្រើនសំរាប់ការរីកចំរើនធំធាត់នៃផ្លែ ។នៅក្នុងវគ្គនេះដែរត្រូវផ្តល់ទឹកចំនួន ៧-១០ ថ្ងៃ ម្តងទៅតាមប្រភេទដី អាកាសធាតុ និងវិធីសាស្រ្តនៃការផ្តល់ដូចជាបាញ់ទឹកផ្សើមពីលើ ឬបញ្ចូលទៅ តាមចន្លោះជួរ ។ វាជាដំណាំដែលធន់ទ្រាំទៅនឹងភាពរាំងស្ងួត ហើយធន់ទ្រាំទៅ នឹងអត្រានៃការកើនលើសសំណើមផងដែរ ។

### ៥- ការជ្រើជ្រួយដី និង កំចាត់ស្មៅ



គេអាចដាំបានស្ទើរពេញមួយឆ្នាំព្រោះដំណាំនេះធន់ទ្រាំ ទៅនឹងអាកាសធាតុក្តៅជាងគេចន្លោះពី ២៥-៣០ $^{O}$C តែពិសេសនៅរដូវទឹកសំរកជាការប្រសើរ ។

### ៨- ការស្រោចស្រព



ការផ្តល់ទឹកដល់ដំណាំ វាជាប្រភពនៃការបំលែង និងបំបែកធាតុនៃសារធាតុចិញ្ចឹមយ៉ាងសំខាន់ ប៉ុន្តែត្រូវគោរពទៅវគ្គលូតលាស់របស់វា ដំបូងវាត្រូវការសំណើមជាមធ្យម របៀតដល់ពន្លូតទងមានសន្លឹក ២-៣ សន្លឹក ក្នុង ករណីដីតាមតំបន់ខ្ពង់រាបខ្វះ សំណើម តែដីល្បាប់មាត់ទន្លេ សំបូរដោយប្រភព ទឹកក្រោមដី ត្រសក់ស្រូវអាចលូត លាស់បានគេស្រោចទឹកតែ ៣-៤ថ្ងៃ ក្រោយពីដាំតែប៉ុណ្ណោះ។ ចាប់ពីត្រសក់ចេញផ្កា

ដែលបានដាក់មុនដាំ ឬដែល មានស្រាប់នៅក្នុងដីមានការវិវត្តន៍យឺតនិងកង្វះខាត ។ ដូច្នេះគេចែកចេញនូវការផ្តល់ជីចំនួន ៣លើកបន្ថែមទៀតគឺ:

- ការបំប៉នលើកទី១ ក្រោយពីត្រសក់មានសន្លឹក ២-៣សន្លឹក ១០-១៥ ថ្ងៃក្រោយដាំ ពេលនោះវាត្រូវការសារធាតុឯទៀត ដូចនេះគេត្រូវយកជីអ៊ុយរ៉េទៅលាយទឹកស្រោច ក្នុងកំរិត ៣៥គក្រ១ហាត (៣០-៣៥ក្រាម លាយទឹក២០លីត្រ) ស្រោចតាមគុម្ពឱ្យជោគ ។

- ការបំប៉នលើកទី ២ ច្រើនតែធ្វើឡើងក្នុងវគ្គជ្រំជ្រួយដី (១៨-២០ថ្ងៃក្រោយដាំ) ដោយយកជី ១៥.១៥.១៥ ចំនួន ១០០-១២០ គ.ក្រ សំរាប់ផ្ទៃដី ១ ហ.ត ដោយពោយជីជុំវិញគល់ហើយពូនដីលុប ឬពូនគល់ហើយយកជីទៅកាប់ដាក់ក្បែរគល់ក៏បាន ក្រោយពេលដាក់ជី ហើយត្រូវស្រោចទឹកជុំវិញគល់ឱ្យសើម ដើម្បីឱ្យជីរលាយបានលឿន

- ការបំប៉នជីលើកទី ៣ ការបំប៉នជីលើកនេះ គេចែកចេញជា ២វិធីសាស្ត្រទៅ តាមគោលបំណងនៃផលិតកម្ម ដូចជា:

  - ការផលិតជាបន្លែ: គឺប្រមូលយកផ្លែខ្ចី ក្រោយពីប្រមូលផ្លែខ្ចីបាន ២-៣លើក គេត្រូវយកជីអ៊ុយរ៉េទៅពោយជុំវិញគល់ហើយស្រោចទឹកឱ្យជោគក្នុង ១ ហ.ត ចំនួន ៥០-៧០ គ.ក្រ ។
  - ការផលិតជាផ្លែទុំ: ត្រូវយកជីអ៊ុយរ៉េចំនួន ៥០ គ.ក្រ លាយនឹងជីប៉ូតាស្យូម

ការជ្រំជ្រួយដីមានប្រយោជន៍យ៉ាងសំខាន់ គឺធ្វើឱ្យដីធូរឡើងវិញ ព្រមទាំងបន្ថយការដុះស្មៅ ធ្វើឱ្យមានបន្ទុកខ្យល់ផ្លាស់ប្តូរបានល្អ ។ ក្នុងករណីចំការមានស្មៅ ច្រើនគេត្រូវជំរះយកស្មៅចេញឱ្យស្អាតជាមុនសិនហើយ ជ្រំជ្រួយដីពូនគល់តាម ក្រោយរបៀបជ្រុំ គឺជ្រុំឱ្យផុសពេញចំការ ប៉ុន្តែការពូនឱ្យត្រូវគល់ព្រមទាំងថ្នាំង ចំនួន ២-៣ថ្នាំង ធ្វើឡើងក្រោយពីត្រសក់ពន្លូតទងបាន ៥-៦ ថ្នាំង អាយុកាលពី ១៨-២០ថ្ងៃក្រោយដាំ ។

## ៦- ការប្រើប្រាស់ជី

ការផ្តល់សារធាតុចិញ្ចឹមបន្ថែម មានសារៈសំខាន់បំផុត ព្រោះសារធាតុចិញ្ចឹម



**វិធានការការពារជំងឺ** គេត្រូវជ្រើសរើសរដូវ ប្រើពូជធន់ ប្តូរមុខដំណាំអនាម័យចំការ សំអាតគ្រាប់ពូជជាមុន គ្រាប់ពូជលាយជាមួយថ្នាំមុនដាំក្រោយពីដុះពន្លកត្រូវយកលូលុយស្បុងថ្នាំផ្សិតទៅបាញ់ការពារនិង ជាពិសេសពេលលេចចេញសញ្ញា ដំបូងត្រូវទប់ស្កាត់ជាមុន បន្ថយការស្រោចទឹក និងការដាក់ជីអាសូត ។

## ២- ក្រុមជំងឺបង្កឡើងដោយវីរុស

មានវីរុសជាច្រើនប្រភេទតែងតែបំផ្លាញដំណាំអំបូរត្រសក់ប៉ុន្តែត្រសក់ស្រូវធន់ទ្រាំជាងគេ ។ នៅក្នុងនោះគេសង្កេតឃើញជំងឺវីរុសមួយប្រភេទ ដែលត្រូវបានចម្លង ដោយសារពពួកចៃ ធ្វើឱ្យស្លឹកត្រសក់រួញខ្វរ បន្ថយការលូតលាស់ ក្នុងករណីផ្លែទុំធ្វើឱ្យ បាត់បង់រសជាតិ ។ គេអាចដឹងមុនបាននូវវត្តមានរបស់សត្វចៃដោយសារតែក្រុម ស្រមោចតោងឡើងដើមត្រសក់ពេលនោះត្រូវមានវិធានការទប់ទល់ ជាមុនកាលណាលេចចេញនូវសញ្ញារួញ ហើយត្រូវតែដកដើមចេញពី ចំការនូវដើមដែលរួញដោយពុំមានថ្នាំព្យាបាលមេរោគនេះឡើយ ។



ចំនួន ៥០ - ៦០គក្រ លាយបញ្ចូលគ្នាហើយកប់ក្បែរៗគុម្ព ក្រោយពីត្រសក់ចេញផ្កា បាន ២០ - ២៥ថ្ងៃ ។

## III. អំពីជំងឺ និងវិធានការការពារ

ត្រសក់ស្រូវត្រូវបានចាត់បញ្ចូលទៅក្នុងដំណាំធន់ទ្រាំ នឹងជំងឺប៉ុន្តែនៅតែមាន ជំងឺមួយចំនួនដែលអាចបំផ្លាញដំណាំបានគឺ:

## ១- ក្រុមបង្កជំងឺដោយមេរោគផ្សិត

មានជំងឺផ្សិត៣ប្រភេទដែលបំផ្លាញត្រសក់ស្រូវជាញឹកញាប់ជាងគេដូចជា:

- ជំងឺរលួយកូន: ធ្វើឱ្យកូនត្រសក់ខ្ចីៗទើបនឹង ដុះរហូតដល់អាយុ ១៥ ថ្ងៃក្រោយ ដាំតែងតែស្វិតគល់ហើយរលួយ។
- ជំងឺស្វួតស្លឹកពណ៌ត្នោត: ធ្វើឱ្យស្វួតស្លឹកផ្ទាំងៗធុំៗធំ បន្ទាប់មករីករាលដាល ពេញលើផ្ទៃស្លឹកជាពិសេសលេចចេញពី ស្លឹកចាស់ៗមុនគេ រហូតដល់ធ្វើឱ្យផ្លែត្រសក់ ស្រឡាកខ្លោចសំបកដូចដំបៅ វាគ្រោះថ្នាក់សំរាប់ការផលិតជាផ្លែទុំ ។
- ជំងឺផ្សិតម្សៅលើស្លឹក: ដំបូងវាលេចចេញកំណកម្សៅជាកញ្ចុំៗលើផ្ទៃស្លឹកបន្ទាប់មកចំណុចនេះរីករាលដាលធំឡើងៗ និង ច្រើនឡើងៗជាពិសេសនៅរដូវត្រជាក់ ស្ងួត (រដូវរំហើយ) ក្រោយមកស្លឹកត្រសក់ទៅជាពណ៌ប្រផេះហើយម្សៅសស្រអាប់ហុយពេលមានខ្យល់បក់ធ្វើឱ្យស្លឹកស្ងួតនិងជ្រុះ។

- មមាចជញ្ជាក់ស្លឹក
- រុយស
- មមង់ជញ្ជក់ស្លឹក

វាច្រើនតែជញ្ជក់យករុក្ខរសធ្វើឱ្យស្លឹកស្ងួត បន្ថយការលូតលាស់ ហើយបង្កឱ្យកើតជំងឺ។ វិធានការការពារ នឹងកំចាត់គឺប្រើពូជធន់និងគ្រប់គ្រងវត្តមានរបស់វាមុនពេលលេចចេញនូវទ្រង់ទ្រាយទៅតាមគ្រោះថ្នាក់ ទៅតាមវិធីសាស្ត្រដែលអាចធ្វើទៅបាន ។

### ២- សត្វល្អិតស៊ីបំផ្លាញផ្កាល់

នៅក្នុងក្រុមនេះមានសត្វល្អិតខ្លះជាដង្កូវ ខ្លះទៀតជាខ្មុងស្លាបរឹងតែងតែករកេរ កាត់ និងចោះស៊ីបំផ្លាញ ដូចជា:

- អណ្តើកមាសពណ៌លឿង: វាស៊ីស្លឹកកូទីឡេដុង ស៊ីត្រួយ ស៊ីផ្កា ក្តិបខ្ចីៗធ្វើឱ្យ ត្រសក់ក្រិនលូតលាស់យឺត ច្រើនចេញបំផ្លាញពេលព្រឹកនិងពេលល្ងាច ពេលថ្ងៃ ជ្រក ក្រោមស្លឹក ។
- ដង្កូវបៃតងមូរស្លឹក: តែងបំផ្លាញត្រួយខ្ចីៗ និងផ្កាទើបនិងរីកលើ ដំណាំអំបូរត្រសក់ទាំងអស់ ហើយពេលថ្ងៃស្ថិតនៅក្នុងស្បែរមូររុំនឹងត្រួយ វាមានពណ៌ដូចត្រួយ ត្រសក់។
- ដង្កូវចោះផ្លែ: វាតែងតែចោះស៊ីក្តិបខ្ចីៗ ហើយរូងចូលទៅក្នុងផ្លែត្រសក់ធ្វើ

### ៣- ក្រុមជំងឺបង្កដោយបាក់តេរី

មានបាក់តេរី ២ប្រភេទដែលធ្វើឱ្យត្រសក់ស្រូវខូចខាតគឺ:

- បាក់តេរីធ្វើឱ្យស្រពោនស្លឹក តែងតែបង្កដោយមេរោគ ។វាតែងធ្វើឱ្យ ត្រសក់ស្រូវងាប់ក្នុងវគ្គចេញផ្លែ វាឆ្លងបានដោយរហ័សតាមរយៈទឹក ដី និង សត្វល្អិត ឈ្មោះថា ខ្មុងត្រសក់ ។
- បាក់តេរីធ្វើឱ្យរលួយផ្លែ ដែលបណ្តាលឱ្យរលួយពេល ត្រសក់ផ្លែចាស់មិនទាន់ ទុំ គឺជាំសំបកដុំៗ ហើយសាច់ខាងក្នុងរលួយជាស្រទាប់ៗ។ ដើម្បីទប់ទល់ទៅនឹងជំងឺនេះ គេត្រូវជ្រើសរើសពូជឱ្យបានល្អ ប្តូរមុខដំណាំពន្យារពេលដាំឱ្យច្រើនរដូវដុតដីសំរាប់ បណ្តុះកូនឱ្យងាប់មេរោគ សំអាតឧបករណ៍បណ្តុះទប់ស្កាត់ ។

## IV. សត្វល្អិតចង្រៃ និងវិធានការការពារ

សត្វល្អិតជាច្រើនប្រភេទដែលតែងស៊ីបំផ្លាញ និងចម្លងជំងឺផ្សេងៗក្នុងនោះមាន:

### ១- សត្វល្អិតជាភ្នាក់ងារចម្លងរោគ

មានសត្វល្អិតជាភ្នាក់ងារបង្ករោគជាច្រើនប្រភេទ ដែលតែងតែបំផ្លាញ ហើយបន្សល់ទុកនូវជំងឺ ជាពិសេសជំងឺ វីរុសដូចជា ៖

- ចៃខ្មៅ
- ចៃបៃតង

ត្រសក់ស្រូវអាចប្រមូលផលបាន (បន្លែ) ក្រោយពីដាំបានរយៈពេល ៤៥-៥០ ថ្ងៃ ក្រោយដាំ ជាលើកដំបូង គេប្រមូលយកផ្លែខ្ចីៗសំរាប់ធ្វើជាបន្លែស្រស់ ឬជ្រក់នៅតំបន់ ខ្លះក្នុងខេត្តកំពង់ចាម គេយកទៅធ្វើជាត្រសក់ត្រៀម ឬត្រសក់ចារ ។ ការប្រមូលផល ធ្វើឡើង ៣-៤ថ្ងៃម្តងៗ ហើយធ្វើឡើងជាច្រើនដង ក្នុងមួយវគ្គជីវិតរបស់វា ទិន្នផល ជាមធ្យមគឺ ៨-១១តោន នៅក្នុងតំបន់មាត់ទន្លេ ...។ របៀបប្រមូលផលគឺគេប្រើ កន្ត្រៃកាត់យកផ្លែ ដើម្បីរក្សាទុកផ្លែបានយូរក្រោយពីកាត់ហើយ យកមករក្សាទុក នៅក្នុងម្លប់ភ្លាម និងរៀបចូលទៅក្នុងកន្លែងស្ងួតមិនឱ្យរលួតសំបកឡើយ ព្រោះសំបកវាស្តើង កាលណាប៉ះទង្គិចខ្លាំងបាត់បង់នូវសោភ័ណភាពទីផ្សារ ។

ចំពោះការប្រមូលផលផ្លែទុំ គេត្រូវទុកត្រសក់ឱ្យទុំពេញលក្ខណៈ រហូតដល់ របេះទងខ្លួនវា ។ នៅក្នុងចំការគេអាចដឹងត្រសក់ទុំបានដោយសារ រសក្លិនក្រអូបរបស់ វាតែមិនលើសពី ៦៥-៧០ថ្ងៃក្រោយដាំ គេត្រូវរើសយកផ្លែទុំមកទុកដាក់កន្លែង



ឱ្យផ្លែស្អុយ ដង្កូវប្រភេទនេះបំផ្លាញដំណាំយកផ្លែស្ទើរតែទាំងអស់ ។

- រុយទិចផ្លែខ្ចីៗ ដំណាំអំបូរត្រសក់ធ្វើឱ្យក្តិបស្អុយៈ លែងលូតលាស់ ដោយ ព្ញបញ្ចូលពងរបស់វាទៅភ្ញាស់នៅក្នុងផ្លែនោះ ។

ដើម្បីទប់ស្កាត់នូវកត្តាចង្រៃប្រភេទនេះ គេមានវិធានការជាច្រើនដូចជា ដាំដំណាំចំរុះយកត្រសក់ស្រូវដាំជា មួយថ្នាំជក់ ជាមួយពោត ជាមួយនឹង ប៉េងប៉ោះ សំអាតចំការឱ្យបានស្អាត ជ្រើសរើសពូជឱ្យសមស្រប នឹងផ្តល់ ទឹកឱ្យបានគ្រប់គ្រាន់គ្រប់គ្រងសត្វទាំង នេះមុនពេលលេចចេញជាមេចំណាស់ ប្រសិទ្ធិភាពល្អគឺកំចាត់វាក្នុងដំណាក់កាលជាកូនដង្កូវ ទៅតាមវិធីសាស្ត្រដែលអាចធ្វើទៅបាន ។

## V. ការប្រមូលផល

